# សុន្ទរកថាគន្លឹះរបស់
# ឯកឧត្តម ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ
# ថ្លែងក្នុងពិធីផ្សព្វផ្សាយ
# របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបាន
# គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ២០១៦-២០៣០

**ថ្ងៃចន្ទ ១០រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤**
**សណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០**

**លោក និក បូរ៉េសហ្វត** Nick Boresford **តំណាងអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា**!

**ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ**

**ឯកឧត្តម លោកជំទាវ អភិបាល អភិបាលរង នៃគណៈអភិបាល រាជធានី ខេត្ត**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ដៃគូអភិវឌ្ឍ**

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី**

១. ថ្ងៃនេះ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងមានសេចក្តីរីករាយជាអនេក ដោយបានមកចូលរួមជាអធិបតីក្នុងពិធីផ្សព្វផ្សាយ ***របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០*** នាថ្ងៃនេះ។

២. ជំនួសមុខឱ្យក្រសួងផែនការ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការយ៉ាងជិតស្និទ្ធរបស់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជាមួយក្រសួងផែនការ ក្នុងការផ្តល់ធាតុចូល ការពិភាក្សា និងផ្តល់អនុសាសន៍កែតម្រូវលើសេចក្តីព្រាងរបាយការណ៍នេះ រហូតទទួលបានជោគជ័យក្នុងការរៀបចំចេញនូវឯកសាររបាយការណ៍ ដែលមានលក្ខណៈពេញលេញ គ្រប់ជ្រុងជ្រោយ និងបង្ហាញចេញនូវលទ្ធផលជាក់ស្តែង ដែលបានអនុវត្តដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា

និងភាគីពាក់ព័ន្ធនានា។ ខ្ញុំក៏សូមសម្ដែងនូវការអបអរសាទរ ចំពោះលទ្ធផលល្អប្រសើរដែលទទួលបានក្នុងការធ្វើឱ្យសម្រេចបាននូវចំណុចដៅនានា ក្នុងឆ្នាំដំបូងរបស់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា គិតត្រឹមដំណាច់ឆ្នាំ២០១៩នេះ។

៣. ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធនានា ជាពិសេស ការិយាល័យអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (UNRC) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) មូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF) ដែលបានផ្ដល់នូវកិច្ចសហការគ្នាយ៉ាងស្អិតរមួត និងផ្ដល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និង ហិរញ្ញវត្ថុដល់ការអនុវត្តសកម្មភាពនានា ដែលរួមចំណែកដល់ការធ្វើឱ្យមានវឌ្ឍនភាព នៃការសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា និងបានរួមចំណែកគាំទ្រដល់ដំណើរការនៃការរៀបចំ***របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា*** នេះ។

## ឯកឧត្ដម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី

៤. យើងមានការចាំបាច់ ក្នុងការបង្ហាញចេញនូវលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងរយៈពេលកន្លងមក ត្រឹមឆ្នាំ២០១៩ ពាក់ព័ន្ធនឹងវឌ្ឍនភាពនៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា និងការរួមចំណែកធ្វើឱ្យសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពសាកល ទោះបីជាស្ថានភាពនៃការរីករាលដាលនៃមេរោគកូវីដ-១៩ នៅបន្តរាតត្បាតទាំងកម្ពុជា និង ពិភពលោកក៏ដោយ។ ទោះជាដូចនេះក្ដី យើងក៏នៅតែអនុវត្តវិធានការនានាយ៉ាងខ្ជាប់ខ្ជួន តាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ពាក់ព័ន្ធនឹងអនាម័យ និងគម្លាតសង្គម នៅពេលយើងរៀបចំពិធីផ្សព្វផ្សាយរបស់យើងនាពេលនេះ។

៥. ***របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា*** នេះ គឺជារបាយការណ៍សម្រាប់បំពេញបន្ថែម ដល់***របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តឆ្នាំ២០១៩*** ដែលត្រូវបានរៀបចំឡើងដោយមានលក្ខណៈបន្ទាន់តាមតម្រូវការជាក់ស្ដែង គឺត្រូវចាប់ផ្ដើមរៀបចំនៅខែកុម្ភៈឆ្នាំ២០១៩ និងត្រូវបញ្ចប់ឱ្យរួចរាល់នៅខែមិថុនា ឆ្នាំ២០១៩ ព្រោះ***របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តឆ្នាំ២០១៩*** នេះ ត្រូវយកទៅបង្ហាញនៅក្នុងវេទិកាកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ នាថ្ងៃទី១៦ ខែ

កម្ពុជា ឆ្នាំ២០១៩ នៅទីស្នាក់ការកណ្តាលអង្គការសហប្រជាជាតិ នាបុរីញ៉ូយ៉ក សហរដ្ឋអាមេរិក។ ដោយសារការរៀបចំមានលក្ខណៈបន្ទាន់ យើងពុំមានព័ត៌មាននិងទិន្នន័យគ្រប់គ្រាន់ សម្រាប់របាយការណ៍នោះ ជាពិសេសព័ត៌មាននិងទិន្នន័យឆ្នាំ២០១៩ សម្រាប់សូចនាករទាំងអស់របស់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា។ ដើម្បីបំពេញបន្ថែមលើរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តឆ្នាំ២០១៩ ក្រសួងផែនការបានផ្តួចផ្តើមរៀបចំ ***របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា*** នេះ ឡើង ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធផ្សេងទៀត។

៦. គោលបំណងសំខាន់របស់របាយការណ៍វឌ្ឍនភាពនេះ គឺបង្ហាញពីលទ្ធផលនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ លើការសម្រេចបាន គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ដោយផ្អែកលើរបាយការណ៍បែបគុណភាព និងទិន្នន័យបែបបរិមាណ រហូតត្រឹមឆ្នាំ២០១៩។ លទ្ធផលដែលសម្រេចបានដោយ ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនានា នេះ គឺជាការរៀបចំនូវគម្រោងផែនការ និងសកម្មភាពនានា ដើម្បីអនុវត្តក្នុងគោលបំណងធ្វើឱ្យសម្រេចបាន នូវគោលដៅនានា នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា នេះ តាមវិស័យនីមួយៗ។

៧. ថ្ងៃនេះ យើងចូលរួមអបអរសាទរ និងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នូវសមិទ្ធផលដែលយើងទាំងអស់គ្នាបានខិតខំរួមគ្នាសម្រេចបាន។ សមិទ្ធផលនេះ គឺជាការបង្ហាញឱ្យឃើញច្បាស់ ពីការប្រែក្លាយការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលជាសមាជិកមួយរបស់អង្គការសហប្រជាជាតិ ក្នុងការអនុវត្ត និងរួមចំណែកធ្វើឱ្យសម្រេចបានរបៀបវារៈឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ។ ជាមួយគ្នានេះ លទ្ធផលនេះក៏ជាការបញ្ជាក់ឱ្យឃើញពីការរួបរួមសាមគ្គី និងសហការគ្នាយ៉ាងជិតស្និទ្ធពីគ្រប់ភាគីទាំងអស់ ទាំងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍ សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និងភាគីដែលមានចំណែកពាក់ព័ន្ធផ្សេងទៀត ក្នុងការរួមចំណែកធ្វើឱ្យកើតមានឡើង នូវសមិទ្ធផលគួរទីជាមោទនៈ ដែលយើងបាននិងកំពុងធ្វើការផ្សព្វផ្សាយនៅពេលនេះ។

## ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី

៨. ការពិនិត្យមើលពីលទ្ធផលនៃការសម្រេចបាន គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា គឺជាការវាយតម្លៃពីការសម្រេចបាន តាមឆ្នាំនីមួយៗ របស់សូចនាករ និងចំណុចដៅនានា តាមគោលដៅនីមួយៗ ក្នុងគោលដៅទាំង១៨។ ការវាយតម្លៃនេះ គឺផ្អែកជាសំខាន់លើ

លទ្ធផលដែលសម្រេចបានជាក់ស្តែង ដោយធ្វើការប្រៀបធៀបទៅនឹងតម្លៃចំណុចដៅរបស់សូចនាករនីមួយៗ ដែលបានកំណត់ ពីឆ្នាំ២០១៦ ដល់២០១៩។

៩. ក្នុងការវាយតម្លៃវឌ្ឍនភាពនៃសូចនាករនិងចំណុចដៅទាំងនេះ ត្រូវបានបែងចែកនិងបង្ហាញចេញ ជា៣កម្រិត គឺ *(១)* **លើសចំណុចដៅ** គឺជាការបង្ហាញឱ្យឃើញពីលទ្ធផលល្អប្រសើរនៃការអនុវត្ត ដោយសម្រេចបានលើសតម្លៃចំណុចដៅដែលបានកំណត់១០% នៅក្នុងឆ្នាំអនុវត្តនីមួយៗ *(២)* **ស្ថិតលើគន្លងឈានទៅសម្រេចបាន** គឺជាការបង្ហាញឱ្យឃើញពីលទ្ធផលល្អនៃការអនុវត្ត ដោយសម្រេចបាននៅចន្លោះពីរវាងក្រោមតម្លៃចំណុចដៅដែលបានកំណត់ត្រឹម១០% និងលើសតម្លៃចំណុចដៅដែលបានកំណត់ត្រឹម១០% នៅក្នុងឆ្នាំអនុវត្តនីមួយៗ និង *(៣)* **ទាបជាងចំណុចដៅ** គឺជាការបង្ហាញឱ្យឃើញលទ្ធផលនៃការអនុវត្ត ដែលសម្រេចបានទាបជាងតម្លៃចំណុចដៅដែលបានកំណត់ពី១០% ឡើងទៅ នៅក្នុងឆ្នាំអនុវត្តនីមួយៗ។

១០. ផ្អែកលើលទ្ធផលដែលទទួលបាន និងបញ្ជាក់ក្នុងរបាយការណ៍នេះ កម្ពុជាសម្រេចបានសមិទ្ធផលមួយល្អលើសូចនាករ និងចំណុចដៅទាំងអស់ ដែលចំណុចដៅប្រមាណ៥៦ក្នុងចំណោមចំនួន៨៨ (ស្មើនឹង៦៣,៦៤%) ស្ថិតលើគន្លងឈានទៅសម្រេចបាន ឬសម្រេចលើស ចំណុចដៅដែលបានកំណត់ និង មានតែចំណុចដៅចំនួន១៤ (ជិត១៦%) ប៉ុណ្ណោះដែលសម្រេចបានទាបជាងចំណុចដៅដែលបានកំណត់។

១១. ទោះជាដូចនេះក្តី ក្នុងឆ្នាំ២០១៩ មានសូចនាករ ឬចំណុចដៅមួយចំនួន មិនមានទិន្នន័យសម្រាប់វាយតម្លៃទេ។ ក្នុងចំណោមចំណុចដៅចំនួន៨៨ មានចំនួន១៨ (ស្មើនឹង២០,៤៥%) គ្មានទិន្ន័យ ដែលក្នុងនោះ មានតែប្រមាណ១ភាគ៣ ប៉ុណ្ណោះដែលពុំមានប្រភពទិន្នន័យ ចំណែកឯសូចនាករប្រមាណ២ភាគ៣ ទៀត មានប្រភពទិន្នន័យគាំទ្រ តែពុំមានវដ្តទិន្នន័យផលិតសម្រាប់ការវាយតម្លៃលទ្ធផលអនុវត្តគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ក្នុងឆ្នាំ២០១៩ នេះទេ ដូចនេះ អាចចាត់ទុកថា ពុំមានទិន្នន័យក្នុងឆ្នាំ២០១៩ តែនឹងអាចមានទិន្ន័យគាំទ្រនៅឆ្នាំខាងមុខ ដែលមានវដ្តទិន្ន័យផលិត។ ក្រុមការងារក្រសួងផែនការ **ឯកឧត្តម ថេង បញ្ញាធន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកផែនការ នឹងធ្វើបទបង្ហាញលម្អិតពីលទ្ធផលនៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា នេះ។

## ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី

១២. ដោយយោងតាមសំណូមពររបស់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធមួយចំនួន ក្រសួងផែនការ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា បានយល់ឃើញពីភាព

ចាំបាច់ ក្នុងការពិនិត្យមើលឡើងវិញនូវបញ្ជីសូចនាករ និងចំណុចដៅ របស់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ជាពិសេសសូចនាករ ដែលពុំមានទិន្នន័យគាំទ្រ។ ភាពខ្វះចន្លោះទិន្នន័យនេះ ធ្វើឱ្យការវាយតម្លៃពីវឌ្ឍនភាពនៃការសម្រេចបាន គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា មានលក្ខណៈមិនពេញលេញ។ ទោះជាដូចនេះក្តី យើងគួរផ្តោតតែលើសូចនាករដែលពុំមានប្រភពទិន្នន័យគាំទ្រប្រមាណ១ភាគ៣ នៃសូចនាករដែលពុំមានទិន្នន័យគាំទ្រប៉ុណ្ណោះ។

១៣. បន្ថែមលើការពិនិត្យមើលសូចនាករដែលពុំមានប្រភពទិន្ន័យគាំទ្រ យើងក៏នឹងពិចារណាទទួលយកសូចនាករនានា ដែលស្នើឡើងដោយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ និងដែលរួមចំណែកធ្វើឱ្យសម្រេចបាន ចំណុចដៅ និងគោលដៅនានា របស់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ដាក់បញ្ចូលក្នុងបញ្ជីសូចនាករ។ ជាមួយគ្នានេះ ដោយសារការរីករាលដាលនៃមេរោគ-កូវីដ១៩ និងតាមប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងវេទិកាសេដ្ឋកិច្ចពិភពលោក កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ដែលបានស្នើឱ្យអង្គការសហប្រជាជាតិពិនិត្យមើលឡើងវិញពីគោលដៅ ចំណុចដៅរបស់***គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ២០១៦-២០៣០*** ថាតើគួររក្សាឆ្នាំកំណត់ត្រឹម២០៣០ ដដែល ឬត្រូវពន្យារពេល ដោយសារយើងមិនដឹងថា កូវីត-១៩ ចប់នៅពេលណា យើងក៏ត្រូវពិនិត្យមើលឡើងវិញផងដែរ នូវតម្លៃចំណុចដៅតាមឆ្នាំនីមួយៗ របស់សូចនាករគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា។

១៤. កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ ក្រសួងផែនការបានដឹកនាំរៀបចំកិច្ចប្រជុំពិភាក្សាម្តងរួចហើយ ពីការកែសម្រួលនេះ តែពុំបានផ្តោតការយកចិត្តទុកដាក់ខ្លាំងលើផលប៉ះពាល់ពីកូវីដ-១៩។ ដូចនេះ ខ្ញុំសូមឱ្យឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី មេត្តាពិនិត្យមើលបន្តទៀត ថាតើតម្លៃចំណុចដៅដែលបានកំណត់សម្រាប់សូចនាករនីមួយៗ មានការចាំបាច់ត្រូវកែសម្រួល ដោយសារផលប៉ះពាល់ពីស្ថានភាពនៃការរីករាលដាល កូវីដ-១៩ឬទេ។ ក្រសួងផែនការនឹងនៅតែបន្តសហការ និងទទួលយកការកែសម្រួលពីឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី បន្ថែមទៀត។

១៥. ទន្ទឹមនឹងការងារប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃមេរោគកូវីដ-១៩ យើងក៏នៅតែបន្តកិច្ចខិតខំប្រឹងប្រែងរបស់យើងនិងសម្រេចបាននូវសមិទ្ធផលជាច្រើនផងទៀត។ នៅពេលយើងធ្វើការផ្សព្វផ្សាយឯកសារ***របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេច***

***បានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា*** នាពេលនេះ ក្រសួងផែនការក៏បានចែកជូនផងដែរនូវឯកសារពាក់ព័ន្ធចំនួន២ទៀត គឺ ***របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តឆ្នាំ២០១៩*** និង ***កូនសៀវភៅតូចគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា***។ខ្ញុំជឿជាក់ថា ឯកសារទាំងនេះ នឹងរួមចំណែកផ្តល់នូវការស្វែងយល់ និងស្រាវជ្រាវបន្ថែម ដល់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី។

## ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី

១៦. ឯកសារ***របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា***នេះ មានសារសំខាន់ណាស់ សម្រាប់បង្ហាញពីលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់យើងទាំងអស់គ្នាកន្លងមក។ បន្ទាប់ពីពិធីផ្សព្វផ្សាយនាថ្ងៃនេះនៅថ្នាក់ជាតិ ក្រសួងផែនការនឹងបន្តធ្វើការផ្សព្វផ្សាយ ឯកសាររបាយការណ៍វឌ្ឍនភាពនេះ និងឯកសារពាក់ព័ន្ធចំនួន២ទៀត នៅថ្នាក់ក្រោមជាតិចំនួន៣តំបន់ ជាបន្តទៀត។

១៧. មុននឹងបញ្ចប់ ជាថ្មីម្តង ខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ាលោក លោកស្រី** ទាំងអស់ ដែលបានចំណាយពេលវេលាដ៏មមាញឹក មកចូលរួមក្នុងពិធីផ្សព្វផ្សាយ***របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា*** នាពេលនេះ។ ខ្ញុំមានជឿជាក់ថា ឯកសាររបាយការណ៍វឌ្ឍនភាព ឆ្នាំ២០១៩នេះ នឹងផ្តល់នូវមូលដ្ឋានសម្រាប់ការរៀបចំផែនការសកម្មភាពអនុវត្តដើម្បីឱ្យសម្រេចបាននូវគោលដៅ និងចំណុចដៅ នៅក្នុងអាណត្តិដែលនៅសល់។ សម្រាប់ផលប៉ះពាល់ពីការរីករាលដាលមេរោគកូវីដ-១៩ ឯកសារនេះ នឹងក្លាយជាឯកសារមូលដ្ឋានសម្រាប់កែសម្រួលបញ្ជីសូចនាករ និងតម្លៃចំណុចដៅ។

១៨. ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូនដល់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា អស់លោក លោកស្រីទាំងអស់ នូវពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមឱ្យជំងឺដ៏កាចសាហាវ កូវីដ ១៩ បានរលាយចាកផុតពីកម្ពុជាកុំបីខាន។

ខ្ញុំសូមប្រកាសបើកជាផ្លូវការនូវ **ពិធីផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាពឆ្នាំ ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០** ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**